01062728

E338

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 06 / 02 / 2015
ម៉ោង (Time/Heure) : 14:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥

**ជូនចំពោះ៖ ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖ លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖ ឯកសារពាក់ព័ន្ធនឹងលោកស្រី Elizabeth BECKER និងលោក Richard DUDMAN ដែលបានដាក់ក្នុងសំណុំរឿងដោយអង្គជំនុំជម្រះសាលាដំបូងតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន**

១. អង្គជំនុំជម្រះសាលាដំបូងបានដាក់ក្នុងសំណុំរឿងនូវឯកសារមួយចំនួន ដែលពាក់ព័ន្ធនឹងការធ្វើសក្ខីកម្មនាពេលខាងមុខរបស់លោកស្រី Elizabeth BECKER និងលោក Richard DUDMAN។

*លោកស្រី Elizabeth BECKER*

២. ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាបានស្នើសុំដាក់បញ្ចូលទៅក្នុងសំណុំរឿង ០០២/០១ នូវរូបថតពណ៌ធម្មជាតិចំនួនដប់ពីរសន្លឹកដែលលោកស្រី Elizabeth BECKER បានថតក្នុងអំឡុងពេលដែលគាត់បានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងស្នើសុំឲ្យអង្គជំនុំជម្រះទទួលយករូបថតទាំង

E338

នេះធ្វើជាភស្តុតាង (ឯកសារ E264/2 ដោយមានភ្ជាប់រូបថតមកជាមួយនឹងសំណើសុំ)។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះមិនបានស្តាប់សក្ខីកម្មរបស់លោកស្រី Elizabeth BECKER ដោយសារលោក អៀង សារី ត្រូវចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ហើយអង្គភាពបកប្រែភាសាបានផ្អាកការងាររបស់ខ្លួនកាលពីខែមីនា ឆ្នាំ ២០១៣ (*សូមអានឯកសារ* E264/3)។ ជាលទ្ធផល អង្គជំនុំជម្រះមិនបានសម្រេចលើសំណើសុំ E264/2 នេះទេ។ បច្ចុប្បន្ននេះ អង្គជំនុំ-ជម្រះមានបំណងកោះហៅលោកស្រី Elizabeth BECKER មកផ្តល់ភស្តុតាងក្នុងសំណុំរឿង ០០២/០២ ក្នុងអំឡុងពេលនៃសវនាការពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ (ឯកសារ E305/6.1)។

៣. ក្នុងឯកសារ E264/2 សហព្រះរាជអាជ្ញាបានលើកឡើងថា រូបថតទាំងនោះទំនងជាជួយរំលឹកការចងចាំរបស់លោកស្រី Elizabeth BECKER ឬពុំនោះសោតទេ អាចជួយដល់ការផ្តល់សក្ខីកម្មរបស់លោកស្រី (ឯកសារ E264/2 កថាខណ្ឌ ១, ៤)។ រូបថតទាំងនោះបង្ហាញពីទីតាំងមួយចំនួនដែលលោកស្រីបានធ្វើទស្សនកិច្ច បង្ហាញពីស្ថានភាពទូទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅអំឡុងពេលទស្សនកិច្ចរបស់លោកស្រី និងជំនួបប្រជុំរវាងលោកស្រីជាមួយ ប៉ុល ពត និង អៀង សារី (ឯកសារ E264/2 កថាខណ្ឌ ៣, ៤)។ សហព្រះរាជអាជ្ញាក៏បានលើកឡើងដែរថា រូបថតពីរសន្លឹកក្នុងចំណោមរូបថតទាំងនោះ និងរូបថតប្រហាក់ប្រហែលគ្នាមួយចំនួនទៀត មាននៅក្នុងសៀវភៅរបស់លោកស្រី Elizabeth BECKER ដែលមានចំណងជើងថា *នៅពេលសង្គ្រាមរលត់ទៅ៖ កម្ពុជា និងបដិវត្តន៍របស់ខ្មែរក្រហម* ហើយសៀវភៅនេះក៏មាននៅក្នុងសំណុំរឿងរួចហើយដែរ (ឯកសារ E3/20) ។ សហព្រះរាជអាជ្ញាក៏បានលើកឡើងដែរថា រូបថតទាំងនោះគឺជាតឹកតាំងពាក់ព័ន្ធជិតស្និទ្ធទៅនឹងសៀវភៅនោះ (ឯកសារ E264/2 កថាខណ្ឌ ៣, ៥)។ សហព្រះរាជអាជ្ញា បានយករូបថតទាំងនោះចេញពីគេហទំព័រមួយ ហើយក៏មិនបានដឹងថា រូបថតទាំងនោះនឹងអាចរកបាន មុនការចាប់ផ្តើមសំណុំរឿង ០០២ នោះទេ (ឯកសារ E264/2 កថាខណ្ឌ ៥)។ ដោយយោងលើហេតុផលទាំងនេះ សហព្រះរាជ-អាជ្ញាបានលើកឡើងថា ការទទួលយកឯកសារទាំងនេះដាក់បញ្ចូលក្នុងសំណុំរឿង គឺដើម្បីប្រយោជន៍យុត្តិធម៌។

៤. ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភស្តុតាងថ្មី ដែលអង្គជំនុំជម្រះយល់ថា មានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត

E338

ប្រសិនបើភស្តុតាងថ្មីនោះបំពេញលក្ខខណ្ឌតម្រូវ *បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿបាន និង យថាភាព ដូចមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

៥. ក្នុងករណីមួយចំនួន អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាង ដែលមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យតឹងរ៉ឹង នៅពេលដែលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ (ឯកសារ E190 កថាខណ្ឌ ១៩-២១, ឯកសារ E289/2 កថាខណ្ឌ ៣)។ ករណីទាំងនេះរួមមាន ការទទួលយកភស្តុតាងដែលជាប់ពាក់ព័ន្ធជិតស្និទ្ធទៅនឹងឯកសារភស្តុតាង ដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងនៅពេលដែលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើការវាយតម្លៃប្រភពទាំងនោះរួមគ្នា និងនៅពេលដែលភស្តុតាងដែលបានស្នើនោះជាភស្តុតាងដោះបន្ទុក ដែលតម្រូវឱ្យមានការវាយតម្លៃដើម្បីជៀសវាងការសម្រេចសេចក្តីដោយមិនយុត្តិធម៌ ឬនៅពេលដែលភាគីដទៃទៀតមិនជំទាស់ទៅនឹងភស្តុតាងទាំងនោះ (*ជាឧទាហរណ៍ សូមអាន* ឯកសារ E190 និងឯកសារ E172/24/5/1)។

៦. អង្គជំនុំជម្រះយល់ឃើញថា រូបថតទាំងនេះមានភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងមានយថាភាព ហើយពាក់ព័ន្ធជិតស្និទ្ធនឹងឯកសារ E3/20។ ប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើការវាយតម្លៃឯកសារទាំងអស់នេះរួមគ្នា។ រូបថតទាំងនេះក៏មានប្រយោជន៍ជួយរំលឹកការចងចាំរបស់លោកស្រី Elizabeth BECKER ផងដែរ ដោយហេតុថា ដំណើរទស្សនកិច្ចរបស់លោកស្រីមកកម្ពុជាប្រជាធិបតេយ្យ កើតមានឡើងប្រហែលជាតាំងពីសែសិបឆ្នាំមុនម្ល៉េះ។ ហេដូច្នេះ រូបថតទាំងនេះនឹងជួយដល់ការស្វែងរកការពិត។ ដើម្បីជាប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះសាលាដំបូងដាក់រូបថតទាំងនេះក្នុងសំណុំរឿង។

៧. អង្គជំនុំជម្រះក៏បានដាក់ក្នុងសំណុំរឿង និងទទួលយកជាភស្តុតាង នូវឯកសារនាសម័យនោះ ពោលគឺអត្ថបទព័ត៌មានដែលលោកស្រី Elizabeth BECKER បានសរសេរ លិខិតមួយច្បាប់ដែលតំណាងរបស់កម្ពុជាប្រជាធិបតេយ្យបានផ្ញើទៅអង្គការសហប្រជាជាតិ និងរូបថតមួយចំនួនបន្ថែមទៀត ដែលពាក់ព័ន្ធនឹងការធ្វើសក្ខីកម្មរបស់លោកស្រីនាពេលខាងមុខ ហើយដែលនឹងជួយដល់ការស្វែងរកការពិត។ អង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងនេះ *តាមការពិនិត្យជាបឋម* មានភាពពាក់ព័ន្ធ អាចជឿជាក់បាន និងមានយថាភាព ស្របតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង៖

- *អង្គរវត្តទទួលបានតួនាទីនិមិត្តសញ្ញាថ្មី* (Herald Tribune) ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៧៨, ERN (ភាសាអង់គ្លេស) S00014128-00014128

E338

- *កម្ពុជាបិទបាំងព័ត៌មានលម្អិតអំពីទីក្រុងភ្នំពេញ* (IHT) ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៩, ERN (ភាសាអង់គ្លេស) 00419355-00419356

- *"បីម៉ោងក្រោយមក អេរវករបានបាញ់ចូលផ្ទះរបស់យើង ភ្ជង់សម្តុតខ្ញុំនឹងកាំភ្លើងខ្លី ហើយក៏បាញ់សម្លាប់ Caldwell នៅកៀកបំផុត" និពន្ធដោយ Dudman (The Guardian) ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៧៨* ERN (ភាសាអង់គ្លេស) S 00014105-00014105

- *ចម្លើយពីរបីទៅនឹងសំណួរដែលនាំរឿង* (International Herald Tribune) ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៧៨ ERN (ភាសាអង់គ្លេស) S 00014114-00014114

- *ឯកសារ អសប* A/34/621-S/13589 ឧបសម្ព័ន្ធ ("ឧក្រិដ្ឋកម្មរបស់អាជ្ញាធរហាណូយប្រឆាំងនឹងកម្ពុជា និង ប្រឆាំងមនុស្សជាតិ") ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៧៩ ERN (ភាសាអង់គ្លេស) 00180075-00180103, ERN (ភាសាបារាំង) 00180133-00180165៖ ជារូបថតព័ត៌មានជាតិថតនៅអំឡុងដំណើរទស្សនកិច្ចរបស់ Elizabeth BECKER នៅកម្ពុជា ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ៖

  i. បញ្ចូលទឹកស្រែ ERN P 00889583-00889583
  ii. ប្រជាជនខ្មែរកំពុងធ្វើការ ERN P 00889584-00889584
  iii. ប្រជាជនខ្មែរកំពុងធ្វើការនៅលើទូក ERN P 00889585-00889585
  iv. ប្រជាជនខ្មែរ ERN P 00889588-00889588
  v. E. B. កំពុងញ៉ាំជាមួយអ្នកដទៃទៀត ERN P 00889593-00889593
  vi. បង្ហាញរាំងនៅប្រាសាទ ERN P 00889594-00889594
  vii. សារី ERN P 00889595-00889595
  viii. នារីលីបារ ERN P 00889598-00889598
  ix. E.B. ជាមួយអ្នកកាសែតពីរនាក់ និងបុរសខ្មែរម្នាក់ ERN P 00889600-00889600
  x. ការបង្ហាញរបស់ E.B. ទី១ ERN P 00889602-00889602 និង
  xi. ការបង្ហាញរបស់ E.B. ទី៤ ERN P 00889604-00889604។

បច្ចុប្បន្ននេះ ភាគីនានាអាចពិនិត្យឯកសារទាំងនេះបាន នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ក្នុងប្រព័ន្ធ Zylab។

E338

លោក ***Richard DUDMAN***

៨. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង ក៏ដាក់បញ្ចូលក្នុងសំណុំរឿងនូវឯកសារដូចខាងក្រោម ដែលពាក់ព័ន្ធនឹងសក្ខីកម្មនាពេលខាងមុខរបស់សាក្សី *Richard DUDMAN*៖

- អត្ថបទសរសេរដោយលោក R. Dudman៖ *សែសិបថ្ងៃជាមួយសត្រូវ* ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៧១ ទំព័រ ៥-១០, ERN (ភាសាអង់គ្លេស) S 00023188-00023193
- មន្ទីរសារព័ត៌មាន និងព័ត៌មាននៃក្រសួងកិច្ចការបរទេស - វិវេចនា "កម្ពុជាប្រជាធិបតេយ្យ" ខែ មីនា ឆ្នាំ ១៩៧៨, ERN (ភាសាបារាំង) S 000501000-00050139 និង
- *អនុលោមភាពគឺចាំបាច់សម្រាប់ការនៅរស់រានមានជីវិតក្នុងប្រទេសកម្ពុជា* (Chicago Tribune) ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៧៨, ERN (ភាសាអង់គ្លេស) 00444937-00444938។

អង្គជំនុំជម្រះចាត់ទុកថា ឯកសារទាំងនេះ ដែលភាគីនានាអាចពិនិត្យបាន នៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងប្រព័ន្ធ Zylab នាពេលបច្ចុប្បន្ន *តាមការពិនិត្យជាបឋម* គឺមានភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងមានយថាភាព តាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។